វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI-វបសអ)
យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល)

# ខប់សែល និង ការបោះឆ្នោតនៅកម្ពុជា
# ឧសភា ២០០៧

## សាវតា

CDRI-វបសអ បានដំណើរការយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល) ដំណាក់កាលទី១ ដោយមានការគាំទ្រពីមូលនិធិអាស៊ី ពីខែសីហា ឆ្នាំ១៩៩៩ រហូតដល់ខែកញ្ញា ឆ្នាំ២០០៣ លើដំណើរការបោះឆ្នោតនៅកម្ពុជាចំនួនពីរលើក ។ មានការរៀបចំកិច្ចប្រជុំប្រចាំខែចំនួន ៥០លើក ដោយមានការចូលរួមពីអ្នកតំណាងជាង ១០០នាក់ មកពីស្ថាប័នរដ្ឋាភិបាល គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) អង្គការឃ្លាំមើលការបោះឆ្នោត ស្ថាប័នសន្តិសុខ អង្គការខាងស្ត្រី និងគណបក្សនយោបាយ ។

ខប់សែលដំណាក់កាលទី២ បានធ្វើឡើងនៅខែកក្កដា ឆ្នាំ២០០៥ និងបានដំណើរការរយៈពេល ៣ឆ្នាំ ដោយមាន ការឧបត្ថមហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។ តាំងពីដំណើរការមក កិច្ចប្រជុំចំនួន ២៣លើក ធ្វើនៅ CDRI-វបសអ ហើយកិច្ចប្រជុំ ២៣លើកដំបូង ក៏បានធ្វើតាម ២៣ខេត្ត ដែលនាំមុខដោយ ការវាយតំលៃតាមតំបន់នីមួយៗ ។ កិច្ចប្រជុំថ្នាក់ខេត្តលើកទី២ ក៏មានការរៀបចំផងដែរ ដោយមានអ្នកចូលរួមប្រមាណ ៦០នាក់ មកពីគណបក្សនយោបាយសំខាន់ៗ គជប ក្រសួងមហាផ្ទៃ អ្នកឃ្លាំមើលការបោះឆ្នោត និងអ្នកពាក់ព័ន្ធផ្សេងទៀត ។ ភាពជោគជ័យកិច្ចប្រជុំក៏មានការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន ដើម្បីបង្កើនការយល់ដឹងដល់សាធារណៈជនទូទៅ ។

## បញ្ហាបានពិភាក្សាអំឡុងពេលកិច្ចប្រជុំខប់សែល

### ១. អត្តសញ្ញាណប័ណ្ណជាតិ

- តាមរយៈកិច្ចប្រជុំ មានការរកឃើញថា តួលេខរបស់នគបាលជាតិស្តីពីចំនួនប្រជាជនកម្ពុជាមានអាយុលើ ១៨ឆ្នាំ ទទួលអត្តសញ្ញាណប័ណ្ណជាតិ ខុសគ្នាពីចំនួន ដែលបានប្រកាសដោយ គជប និងក៏ដូចជា ចំនួនបង្ហាញដោយវិទ្យាស្ថានស្ថិតិជាតិ ។
- បញ្ហាជនអន្តោប្រវេសវៀតណាម ទទួលបានអត្តសញ្ញាណប័ណ្ណ ក៏មានការពិភាក្សាផងដែរ ។ តាមរយៈអ្នកតំណាងក្រសួងមហាផ្ទៃ គេបានស្នើទៅដល់ក្រសួងឱ្យពិនិត្យបញ្ហានេះយ៉ាងហ្មត់ចត់ ។
- ចំពោះបញ្ហាពន្យាពេលផ្តល់អត្តសញ្ញាណប័ណ្ណនៅខេត្តមួយចំនួន ជាពិសេសប្រជាពលរដ្ឋ ដែលត្រូវការ អត្តសញ្ញាណប័ណ្ណ ដើម្បីធ្វើការនៅក្នុងរោងចក្រ បានលើកឡើងថា ឱ្យផ្តល់នេះឱ្យបានលឿន ។
- មានការលើកឡើងថា អត្តសញ្ញាណប័ណ្ណ គួរតែផ្តល់ដោយឃុំ នៅក្នុងការងារត្រៀមរៀបចំឱ្យរួចរាល់នៅទីនោះ និងជំរុញឱ្យផ្តល់អត្តសញ្ញាណប័ណ្ណ ឱ្យបានឆាប់ ។

### ២. ដំណើរការចុះឈ្មោះបោះឆ្នោត

- មានការទទួលស្គាល់ថា កិច្ចខិតខំប្រឹងប្រែងជាច្រើនថែមទៀត ត្រូវការចាំបាច់ដើម្បីធានាថា ព័ត៌មានទាក់ទងការបោះឆ្នោតបានដល់អ្នកបោះឆ្នោត ។ គជប រំពឹងថា អ្នកបោះឆ្នោតអាចប្រើប្រាស់អំឡុងពេលមុនចុះឈ្មោះបោតឆ្នោត ៩ខែ ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០០៦ សំរាប់ការរៀបចំចុះឈ្មោះបោះឆ្នោត ។

- សំរាប់ព័ត៌មានទាក់ទងការបោះឆ្នោតឱ្យបានដល់អ្នកបោះឆ្នោត គជប បានស្នើឱ្យមានកិច្ចសហការលើការផ្សព្វផ្សាយជាមួយអង្គការផ្សេងទៀត ។

៣. សន្តិសុខ

- មានការយល់ស្របថា សន្តិសុខក្នុងការបោះឆ្នោត គឺជាការទទួលខុសត្រូវរួមគ្នារបស់រដ្ឋាភិបាល និងគណបក្សនយោបាយទាំងឡាយ ។ មានការបារម្ភអំពីការបង្ខំឱ្យអ្នកបោះឆ្នោតឱ្យស្មោះត្រង់ចំពោះគណបក្ស នយោបាយ ។ មានការរាយការណ៍ថា អជ្ញាធរមូលដ្ឋានមួយចំនួន បន្តគំរាមកំហែងប្រជាពលរដ្ឋ ដូច្នេះបង្កើតឱ្យមាន បរិយាកាសភ័យខ្លាច ។
- មានកិច្ចខិតខំប្រឹងប្រែងពីអជ្ញាធរមូលដ្ឋាន ក្នុងការរារាំងគណបក្សនយោបាយថ្មីពីបញ្ចេញសិទ្ធិស្របច្បាប់ (ឧ. ការដាក់តាំងផ្លាកសញ្ញាគណបក្ស ការរៀបចំកិច្ចប្រជុំជាមួយសមាជិក ការរៀបចំសិក្ខាសាលា ជាដើម) ។

៤. បញ្ហាផ្សេងៗមួយចំនួនទៀត

- ការទទួល និងដោះស្រាយបណ្តឹង នៅតែជាបញ្ហាស្មុគស្មាញរបស់ គជប ជាពិសេសពាក់ព័ន្ធនិតិវិធី ។ សមត្ថភាពរបស់មន្ត្រីពីគណៈកម្មាធិការឃុំរៀបចំការបោះឆ្នោត ទៅគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត ក្នុងការដោះស្រាយបណ្តឹងនៅមានកំណត់ ហើយការពិចារណាលើការពង្រឹងសមត្ថភាពជារឿងចាំបាច់សំរាប់ពួកគេ ។
- ទោះបីជាការបោះឆ្នោតព្រឹទ្ធសភាលើកទី១ បានធ្វើឡើងរួចហើយក្តី វិសោធនកម្មច្បាប់បោះឆ្នោតព្រឹទ្ធសភានៅតែមានការជជែកដេញដោល ហើយមានការស្នើថា ឱ្យមានអ្នកបោះឆ្នោតផ្សេងទៀត ក្រៅពីមេឃុំ គួរត្រូវរាប់បញ្ចូលផង ។
- បញ្ហាយ៉េនឌ័រ នៅតែបញ្ហាធ្ងន់ធ្ងរ ដែលត្រូវការការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀត ជាពិសេស ការប្តេជ្ញារចិត្តរបស់ប្រធានគណបក្សនយោបាយ ក្នុងការលើកទឹកចិត្តឱ្យស្ត្រីនៅតំបន់ដាច់ស្រយាលឱ្យសកម្មចូលរួមក្នុងមុខដំណែង ដូចជា មេឃុំ និងជីវភាពនយោបាយជាទូទៅ ។ មានការលើកឡើងថា ស្ត្រីគួរតែរាប់ បញ្ចូលទៅបញ្ជីបេក្ខជនឱ្យបានច្រើន ដើម្បីធានាឱ្យមានការចូលរួមខ្ពស់របស់ស្ត្រីក្នុងនយោបាយ ហើយក៏គួរមានការគាំទ្រ និងលើកទឹកចិត្តយ៉ាងខ្លាំងពីសង្គម សហគមន៍ គ្រួសារ និងគណបក្សនយោបាយ ដើម្បីឱ្យស្ត្រីមាន ភាពងាយស្រួលក្នុងការទទួលបានមុខដំណែង ។
- មានការបារម្ភអំពីវិធី គជប បកប្រែច្បាប់បោះឆ្នោត នៅពេលរៀបចំបទប្បញ្ញត្តិ និងនីតិវិធីបោះឆ្នោត ។
- គជប ត្រូវបានគេមើលឃើញថា មានជំហរខ្សោយ ក្នុងការដាក់ទោសអ្នករំលោភគោលការណ៍ និងច្បាប់បោះឆ្នោត ។ យន្តការភាគច្រើនដែលប្រើប្រាស់ដោយ គជប ច្រើនមើលឃើញថា មិនមានប្រសិទ្ធភាព ។
- ការប្រកាសលទ្ធផលបោះឆ្នោតគួរធ្វើនៅក្នុងលក្ខណៈតម្លាភាព បើពុំនោះទេ គជប នឹងបាត់បង់ទំនុកចិត្ត ។ គណបក្សនយោបាយមិនត្រូវអនុញ្ញាតឱ្យប្រកាសលទ្ធផលបោះឆ្នោតទេ ។
- ការរៀបចំការបោះឆ្នោតគួរគិតគូរពីអ្នកបោះឆ្នោតដែលនៅទីដាច់ស្រយាល ដើម្បីជួយឱ្យពួកគេបានចូលរួមបោះឆ្នោតកន្លែងដែលគេរស់នៅ ។
- មានការពិភាក្សាពីការស្នើសុំឱ្យពន្យាពេលដំណាក់កាលចុះឈ្មោះឱ្យច្រើនជាង ២០ថ្ងៃ ។ ការចុះបញ្ជីឱ្យត្រឹមត្រូវនូវទិន្នន័យអ្នកបោះឆ្នោតដូចជា ការសរសេរឈ្មោះ ថ្ងៃខែឆ្នាំកំណើតជាដើម គួរចាត់ទុកជាអទិភាព ។

- ពេលវេលាបោះឆ្នោត គួរត្រូវពន្យាពី ម៉ោង ៣ ទៅដល់ ម៉ោង ៥ ល្ងាច ពីព្រោះអ្នកបោះឆ្នោតរបស់ប្រកបរបរ ចិញ្ចឹមជីវិត ។ ការជ្រើសរើសថ្ងៃបោះឆ្នោតនៅខែ កក្កដា ត្រូវចំពេលវេលាដែលប្រជាជនកំពុងធ្វើស្រែចំការ មានភ្លៀងច្រើន ដែលពិបាកធ្វើដំណើរ ។
- ប្រធានភូមិ ជាមនុស្សសំខាន់ក្នុងការចែកបណ្ណ័ពតិមាន ប៉ុន្តែពួកគេមិនគួរមានវត្តមាននៅទីតាំងបោះឆ្នោត នៅថ្ងៃបោះឆ្នោតទេ ពីព្រោះ គាត់អាចមានឥទ្ធិពលលើអ្នកបោះឆ្នោត ។ មន្ត្រី ប៉ូលីស យោធា និង ខណ្ឌស្រុក បានឃើញឈរនៅទីតាំងបោះឆ្នោត នៅថ្ងៃបោះឆ្នោត ដែលអាចចាត់ទុកថា មានឥទ្ធិពលលើអ្នកបោះឆ្នោត ផងដែរ ។
- អំណោយ និងការបរិចាកផ្សេងៗ មិនត្រូវអនុញ្ញាតដែលចែកជូននៅកំឡុងយុទ្ធនាកាបោះឆ្នោតទេ លើកលែងតែអំណោយសំរាប់គ្រោះធម្មជាតិ ពិព្រោះវាហាក់ដូចជាការអូសទាញផ្ទៃកនយោបាយ ។
- មានភាពកកកុញនៅមុខការិយាល័យបោះឆ្នោត នៅកំឡុងពីរ-បីម៉ោងដំបូងនាថ្ងៃបោះឆ្នោត ដែលអាចធ្វើ ឱ្យអ្នកមកបោះឆ្នោតមិនចង់បោះ ដូច្នេះទាមទារឱ្យកែលំអស្ថានភាពនេះ ។
- ពេលវេលាផ្តល់ឱ្យកម្មកររោងចក្រសំរាប់ធ្វើដំណើរទៅបោះឆ្នោត គឺតិចពេក ។
- មានការលើកឡើងថា គួរចាត់ឱ្យ គជប គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយឯកជននៅកំឡុងយុទ្ធនាកាបោះឆ្នោត បន្ថែមពីលើការរក្សាយុត្តាធិការលើប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។
- សវនកម្មលើចំណាយរបស់គណបក្សនយោបាយ គួរតែ គជប ជាអ្នកធ្វើ នៅរាល់ក្រោយការបោះឆ្នោត នីមួយៗ ដើម្បីធានានូវគុណភាព និងភាពយុត្តិធម៌

**បញ្ហាសំខាន់ៗ និងលទ្ធផលនៃយន្តការ ខប់សៃល ដំណាក់កាលទី២**

**១. ការរីកចំរើនជាទូទៅ**

- ចាប់តាំងពីការបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ កម្ពុជាបានរៀបចំ ការបោះឆ្នោតចំនួន ៥ ទៀតដោយខ្លួនឯងផ្ទាល់ គឺ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ១៩៩៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី១ នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រឆ្នាំ២០០៣ ការបោះឆ្នោតព្រឹទ្ធសភាឆ្នាំ២០០៦ និង ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី២ នៅឆ្នាំ២០០៧ ។ ពីការបោះឆ្នោតមកទៅការបោះឆ្នោតមួយទៀត គេឃើញមានការរីកចំរើនយ៉ាងខ្លាំង ជាពិសេសទាក់ទិននឹងកំហុសឆ្គងបច្ចេកទេស ហើយដំណើរការបោះឆ្នោតក៏ត្រូវបានពង្រឹងផងដែរ ។ យន្តការខប់សៃល ទាំងពីរដំណាក់កាល បានចូលរួមចំណែកការពារ និងដោះស្រាយទំនាស់ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។
- ទោះជាគេសង្កេតឃើញថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧ ប្រព្រឹត្តទៅបានល្អក៏ដោយ ក៏មានភាពមិនប្រក្រតី និងបញ្ហាមួយចំនួនគួរត្រូវដោះស្រាយឱ្យបានរួចរាល់មុនការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៨។

**២. អត្តសញ្ញាណប័ណ្ណ**

- នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់រដ្ឋាភិបាលឆ្នាំ២០០៥ ដោយយោងទៅលើសារៈសំខាន់នៃអត្តសញ្ញាណប័ណ្ណ រដ្ឋាភិបាលបានប្រកាសអាទិភាពការងារចេញអត្តសញ្ញាប័ណ្ណដែលនៅសល់ឱ្យរួចរាល់នៅចុងឆ្នាំ២០០៦ ។ យុទ្ធនាកាចេញអត្តសញ្ញាណប័ណ្ណឆ្នាំ២០០៦ មានជោគជ័យជាទូទៅ ដោយបានចេញឱ្យជនគ្រប់អាយុ ប្រហែល ៩០% ។

- ក្រសួងមហាផ្ទៃបានបញ្ឈប់កិច្ចសន្យាផលិតអត្តសញ្ញាប័ណ្ណឱ្យទៅក្រុមហ៊ុនឯកជនចំនួន ២ ដោយសារកង្វះប្រសិទ្ធភាព និងយឺតយ៉ាវ ។ ចាប់តាំងពីឆ្នាំ២០០៧ ក្រសួងបានបំពាក់បំប៉ន់ដល់គ្រប់ខេត្ត ទាំងអស់នូវរចនាសម្ព័ន្ធធ្វើអត្តសញ្ញាណប័ណ្ណ ។
- អភិបាលរងទីមួយរបស់ខេត្ត ត្រូវបានចាត់តាំងឱ្យចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណនៅពេលដែលអភិបាលខេត្តជាប់រវល់ ។ ក្រៅពីនេះ ក្រសួងមហាផ្ទៃបានបង្កើតគណៈកម្មាធិការពិសេសមួយឱ្យទទួលខុសត្រូវការងារអត្តសញ្ញាណប័ណ្ណនេះ ។

### ៣. ការចុះឈ្មោះ និងបែបបទនៃការចុះឈ្មោះបោះឆ្នោត

- នៅឆ្នាំ២០០៦ ការចុះឈ្មោះបោះឆ្នោតបានបន្ថែមពេលពី ២០ថ្ងៃ ទៅដល់ ២៤ថ្ងៃ ដើម្បីផ្តល់ពេលវេលា ឱ្យបានគ្រប់គ្រាន់ដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកបោះឆ្នោតសំរាប់ធ្វើការចុះឈ្មោះ ។
- គជប និងក្រសួងការងារ បានយល់ព្រមលើការផ្តល់ច្បាប់ឈប់សំរាក ចំនួន ២ថ្ងៃ ដល់កម្មករនៅកំឡុង ការចុះឈ្មោះបោះឆ្នោត និងចេញលិខិតបញ្ជាក់ឱ្យពួកគេសំរាប់ការចុះឈ្មោះនៅខេត្តឆ្ងាយៗ ។

### ៤. សន្តិសុខ

- មានការយល់ស្របជាទូទៅថា ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត ស្ថានភាពសន្តិសុខ ត្រូវបានកែលំអ ហើយ អំពើហឹង្សាក៏ត្រូវបានកាត់បន្ថយដែរ ។
- ទោះជាយ៉ាងនេះក្តី ទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសនៅកំឡុងយុទ្ធនាការបោះឆ្នោត និងនៅ "ថ្ងៃ ស" ( មួយថ្ងៃមុនថ្ងៃបោះឆ្នោត) នៅពេលដែលគណបក្សនយោបាយ ត្រូវបានហាមឃាត់ពីការធ្វើ សកម្មភាពយុទ្ធនាការបោះឆ្នោត ។

### ៥. បញ្ហាផ្សេងៗមួយចំនួនទៀត

- ការពិភាក្សាកាន់តែមានលក្ខណៈបើកចំហ ត្រង់ទៅត្រង់មក និងមានការគោរពគ្នា ទាំងនៅភ្នំពេញ និង នៅតាមបណ្តាខេត្តនានា ក្នុងគោលបំណងស្វែងរកដំណោះស្រាយដោយសន្តិវិធី ជៀសវាងអំពើហឹង្សា និងការយល់ច្រឡំផ្សេងៗ ។
- ដំណើរការរៀបចំការបោះឆ្នោតកាន់តែមានតំលាភាព និងការទទួលខុសត្រូវ ។ រីឯការសហការពីអ្នកពាក់ពន្ធ័ក្នុងការបោះឆ្នោតមានលក្ខណៈកាន់តែប្រសើរទាំងដំណើរការបោះឆ្នោត និងសន្តិសុខ ។
- ទោះជាយ៉ាងណា គេឃើញនៅមានបញ្ហាមួយចំនួន ដូចជា ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយនៅកំឡុងយុទ្ធនាការបោះឆ្នោត និងកំហុសឆ្គងបច្ចេកទេសដទៃទៀត ដែលទាមទារនូវការយកចិត្តទុកដាក់ និងកិច្ចសហការល្អដើម្បីធានាឱ្យមានប្រជាធិបតេយ្យ ។
- ការសន្និដ្ឋានរបស់អ្នកចូលរួមបោះឆ្នោតទាំងអស់នៅក្នុងវគ្គបណ្តុះបណ្តាលរបស់ គជប អាចបញ្ចៀសនូវ ការយល់ច្រឡំលើបែបបទ និងបទប្បញ្ញត្តិក្នុងការបោះឆ្នោតរបស់ គជប ហើយមានការយល់ដឹងកាន់ តែច្រើនឡើងពីច្បាប់បោះឆ្នោត ហេតុនេះជាការធានាឱ្យការបោះឆ្នោតមានភាពរលូន ។ រឿងនេះ ជាគំរូមួយអាចបង្ហាញថាកម្ពុជាអាចខិតខំសិក្សាទាំងអស់គ្នា ដើម្បីកសាង និងពង្រឹងការយល់ដឹង ទំនាក់ទំនង និងទំនុកចិត្ត ។
- យន្តការ ខប់សែល នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានលើកឡើងពីការព្រួយបារម្ភជាបន្តបន្ទាប់រឿងអំណោយ និងការបរិចាកនានា ដែលអាចពាក់ពន្ធ័ទៅនឹងការបោះឆ្នោត ។